# ជំពូក១៖ ប្រវត្តិភពផែនដី
# មេរៀនទី៥៖ ករណីសិក្សាកំណកំណើតបឹងទន្លេសាប

## មេរៀនសង្ខេប

### ១. ការកកើតបឹងទន្លេសាប៖




- ប្រហែល 15000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ ទាបជាងពេលបច្ចុប្បន្ន 100 ម៉ែត្រ ទ្រនទ្វីបងើបឡើងដូចជាខ្សែធ្នូ ខ្ពស់ជាងកម្រិតនីវ៉ូទឹកសមុទ្រ ។
- ប្រហែល 13000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ កើនឡើង 25 ម៉ែត្រ ទ្រនទ្វីបចាប់ផ្ដើមរីកធំ ។
- ប្រហែល 11000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ កើនឡើង 50 ម៉ែត្រ ទ្រនទ្វីបរីកកាន់តែធំ ចាប់ផ្ដើមកើត ឈូងសមុទ្រថៃ។ ទន្លេមេគង្គក្រោមបានបែងចែកជាផ្លូវទឹកពីរ និងទន្លេបាសាក់បានកើតឡើងដំបូង ។
- ប្រហែល 9000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ ឡើងកម្ពស់ 75 ម៉ែត្រ កកើតបឹងតូចៗជាច្រើន និងតំបន់លិចទឹកក៏ចាប់ផ្ដើមកើតដែរ ។
- ប្រហែល 7000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ កើនឡើងរហូតដល់បច្ចុប្បន្ន បឹងតូចៗជាច្រើន និងតំបន់លិចទឹក គឺស្ថិតនៅក្នុងតំបន់បឹងទន្លេសាបបច្ចុប្បន្ន ត្រូវបានបំពេញដោយការហូរចាក់ដីពីល្បាប់ភ្នំ និងតំបន់ដីទាបៗដែលនៅជុំវិញ ។
- ប្រហែល 6000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ បានកើនឡើង 1 ម៉ែត្រ ទៀតខ្ពស់ជាងបច្ចុប្បន្ន បឹងតូចៗ និងតំបន់លិចទឹកដែលជាទីតាំងបឹងទន្លេសាបបានរួមទៅៗ ។
- ប្រហែល 5000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ បានបញ្ឈប់នៅរដូវទឹកជំនន់ ។ ទឹកទន្លេមេគង្គបានហូរត្រឡប់មកវិញ ការហៀរហូរទឹកពីទន្លេចូលទៅកាន់តំបន់ទំនាបលិចទឹកនិងបឹងតូចៗបង្កើតបានជាបឹងដ៏ធំមួយ ដែលនៅរដូវប្រាំងទឹកបឹងនេះបានហូរចូលទៅក្នុងទន្លេមេគង្គវិញ នេះជាដើមកំណើតនៃបឹងទន្លេសាប ។

- ប្រហែល 3000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ  បានចាប់ផ្តើមថយចុះបន្តិចម្តងៗ ស្មើនឹងបច្ចុប្បន្នបានចាប់ផ្តើមកកើតបន្តិចម្តងៗ ដីសណ្តទន្លេមេគង្គ  បឹងទន្លេសាប ដូចជា តំបន់ទឹកដែលរីកនិងរួមមាឧជារៀងរាល់ឆ្នាំ ។ បច្ចុប្បន្នបឹងទន្លេសាបបានផ្តត់ផ្គង់ទឹក ដលផល ដល់ជីវិតប្រជាជនកម្ពុជា សង្គម និង វប្បធម៌ ។ ដីសណ្តទន្លេមេគង្គបាននឹងកំពុងវិវត្តបន្តិចម្តងៗទៅក្នុងសមុទ្រចិនខាងត្បូង  ៕

# ខ្មោយតម្លៃ

I. ចូរប្អូនបំពេញឈ្មោះខាងក្រោមឱ្យបានត្រឹមត្រូវ៖ (២០ពិន្ទុ)

1. ប្រហែល 11000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ កើនឡើង 50 ម៉ែត្រ ទ្រនទ្វីបរីកកាន់តែធំ ចាប់ផ្តើមកើត ឈូងសមុទ្រថៃ ។
2. ប្រហែល 9000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ ឡើងកម្ពស់ 75 ម៉ែត្រ កកើតបឹងតូចៗ ជាច្រើន និង តំបន់លិចទឹក ក៏ចាប់ផ្តើមកើតដែរ ។
3. ប្រហែល 13000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ កើនឡើង 25 ម៉ែត្រ ទ្រនទ្វីបចាប់ផ្តើមរីកធំ ។

II. ចូរប្អូនគូសសញ្ញា☑នៅខាងមុខចម្លើយត្រឹមត្រូវមានតែមួយគត់៖ (២០ពិន្ទុ)

1. កម្រិតនីវ៉ូទឹកសមុទ្រ បានកើនឡើង 1 ម៉ែត្រ ទៀតខ្ពស់ជាងបច្ចុប្បន្ន បឹងតូច ៗ និងតំបន់លិចទឹកដែលជាទីតាំងបឹងទន្លេសាបបានរួមទៅៗគឺនៅប្រហែល

   ☐ ក. 9000ឆ្នាំមុន ☑ ខ. 6000ឆ្នាំមុន ☐ គ. 7000ឆ្នាំមុន

2. កម្រិតនីវ៉ូទឹកសមុទ្រ ឡើងកម្ពស់ 75 ម៉ែត្រ កកើតបឹងតូចៗជាច្រើន និងតំបន់លិចទឹកក៏ចាប់ផ្តើមកើតដែរ គឺនៅប្រហែល

   ☑ ក. 9000ឆ្នាំមុន ☐ ខ.13000ឆ្នាំមុន ☐ គ. 11000ឆ្នាំមុន

3. ប្រហែល 5000 ឆ្នាំមុនកម្រិតនីវ៉ូទឹកសមុទ្របានបញ្ឈប់

   ☐ ក.នៅរដូវទឹកស្រក ☑ ខ. នៅរដូវទឹកជំនន់ ☐ គ.នៅរដូវក្តៅ

# កិច្ចការផ្ទះ

I. នៅប្រហែល១៥០០០ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រដូចម្ដេច?

ចំ- នៅ ប្រហែល 15000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ ទាបជាងពេលបច្ចុប្បន្ន 100 ម៉ែត្រ ទ្រនទ្វីបងើបឡើងដូចជាខ្សែផ្ទេរ ខ្ពស់ជាងកម្រិតនីវ៉ូទឹកសមុទ្រ ។

II. ប្រហែល៣០០០ឆ្នាំមុន តើកម្រិតនីវ៉ូទឹកសមុទ្រកើនដូចម្ដេច?

ចំ- ប្រហែល 3000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ បានចាប់ផ្ដើមថយចុះបន្តិចម្ដងៗ ស្មើនឹងបច្ចុប្បន្ន បានចាប់ផ្ដើមកកើតបន្តិចម្ដងៗដីសណ្ដទន្លេមេគង្គ បឹងទន្លេសាប ដូចជា តំបន់ទឹកដែលរីកនិងរួមមាឌជារៀងរាល់ឆ្នាំ ។

III. ប្រហែល១៣០០០ឆ្នាំមុន តើកម្រិតនីវ៉ូទឹកសមុទ្រកើនដូចម្ដេច?ហើយទ្រនទ្វីបមានលក្ខណៈដូចម្ដេច?

ចំ-ប្រហែល 13000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ កើនឡើង 25 ម៉ែត្រ ទ្រនទ្វីបចាប់ផ្ដើមរីកធំ ។

IV. ចូរនិយាយពីការកកើតបឹងទន្លេសាប។

ចំ- ប្រហែល 5000 ឆ្នាំមុន កម្រិតនីវ៉ូទឹកសមុទ្រ បានបញ្ឈប់ នៅរដូវទឹកជំនន់ ទឹកទន្លេមេគង្គបានហូរត្រឡប់មកវិញ ការហៀរហូរទឹកពីទន្លេចូលទៅកាន់តំបន់ទំនាបលិចទឹកនិងបឹងតូចៗបង្កើតបានជាបឹងដ៏ធំមួយដែលនៅរដូវប្រាំងទឹកបឹងនេះបានហូរចូលទៅក្នុងទន្លេមេគង្គវិញ នេះជាដើមកំណើតនៃ បឹងទន្លេសាប ។

V. បច្ចុប្បន្ន តើបឹងទន្លេសាបបានផ្ដត់ផ្គង់អ្វីខ្លះដល់ប្រជាជនកម្ពុជា?

ចំ- បច្ចុប្បន្នបឹងទន្លេសាបបានផ្គត់ផ្គង់ទឹក ជលផល ដល់ជីវិតប្រជាជនកម្ពុជា សង្គម និង វប្បធម៌ ។ ដីសណ្ដទន្លេមេគង្គបាននឹងកំពុងវិវត្តបន្តិចម្ដងៗទៅក្នុងសមុទ្រចិនខាងត្បូង ៕